**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០១/នស/៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខនស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.–**

អនុក្រឹត្យនេះមានគោលដៅកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដែលស្ថិតក្នុងឃុំត្រពាំងប្រីយ៍ និងឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

**មាត្រា២.–**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- អភិរក្សទីតាំងសំខាន់ៗ ដែលជាមជ្ឈមណ្ឌលនយោបាយចុងក្រោយបង្អស់របស់អតីតអង្គការចាត់តាំងនយោបាយ និងយោធានៃកម្ពុជាប្រជាធិបតេយ្យ ដើម្បីឱ្យសាធារណជនជាតិ និងអន្តរជាតិ យល់ដឹង និងចងចាំអំពីនយោបាយមេដឹកនាំរបស់បនប្រល័យពូជសាសន៍
- ការពារបរិស្ថានធម្មជាតិក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ
- អភិរក្ស និងអភិវឌ្ឍទេសចរណ៍បែបប្រវត្តិសាស្ត្រ និងធម្មជាតិ ។

## ជំពូកទី២

## ការកំណត់តំបន់

**មាត្រា៣.–**

តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងចែកជា២តំបន់គឺ តំបន់លើភ្នំ(តំបន់ក) និង តំបន់ជើងភ្នំ(តំបន់ខ)រួមមាន៖

**១.តំបន់ ក** ជាតំបន់ស្ថិតនៅក្នុងភូមិសាស្ត្រលើជួរភ្នំដងរែក ដែលមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រតូចៗ ចំនួន៦ (ប្រាំមួយ)គឺ ៖

តំបន់ ក១ ៖ កន្លែងដុតខ្មោចប៉ុល ពត មានផ្ទៃក្រឡា ១.២០៧ ហិកតា (មួយហិកតាពីររយប្រាំពីរ) ដែលមាននិយាមកា ៖ A (398811 ; 1585576) B (398890 ; 1585536) C (398836 ; 3585490) D (398832 ; 1585414) E (398752 ; 1585444) ។

តំបន់ ក២ ៖ កន្លែងកាត់ទោសប៉ុល ពត មានផ្ទៃក្រឡា០.៤៤៩ហិកតា (សូន្យហិកតាបួនរយសែសិបប្រាំបួន) ដែលមាននិយាមកា ៖ A (399150 ; 1585570) B (399128 ; 1585528) C (399040 ; 1585581) D (399063 ; 1585616) ។

តំបន់ ក៣ ៖ ផ្ទះតាម៉ុក និងផ្ទះកណ្ដាលលើខ្នងភ្នំដងរែក មានផ្ទៃក្រឡា៣.០២៥ហិកតា (បីហិកតាសូន្យម្ភៃប្រាំ) ដែលមាននិយាមកា ៖ A (401898 ; 1585823) B (401999 ; 1585853) C (402005 ; 1585975) D (401809 ; 1585905) E (401824 ; 1585697) F (401912 ; 1585728) ។

តំបន់ ក៤ ៖ កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០ មានផ្ទៃក្រឡា១.១៤២ហិកតា ( មួយហិកតាមួយរយសែសិបពីរ) ដែលមាននិយាមកា ៖ A (398668 ; 1584420) B (398768 ; 1584430) C (398790 ; 1584318) D (398690 ; 1584308) ។

តំបន់ ក៥ ៖ រោងយាមពីរកន្លែង ផ្ទះប៉ុល ពត ខៀវ សំផន និងជំរំអ្នកនយោបាយរបស់រដ្ឋាភិបាលខ្មែរក្រហមនៅក្បាលទន្សោង មានផ្ទៃក្រឡា១១៧.០៦១ហិកតា ( មួយរយដប់ប្រាំពីរហិកតាសូន្យហុកសិបមួយ) ដែលមាននិយាមកា ៖ A (405193 ; 1588632) B (405738 ; 1588632) C (405888 ; 1586632) D (405193 ; 1586832) ។

តំបន់ ក៦ ៖ ឃ្លាំងដាក់សម្ភារៈជើងភ្នំ មានផ្ទៃក្រឡា១.៧៥២ហិកតា ( មួយហិកតាប្រាំពីររយហាសិបពីរ) ដែលមាននិយាមកា ៖ A (401138 ; 1584684) B (401252 ; 1584710) C (401274 ; 1584562) D(401161 ; 1584534) ។

**២.តំបន់ ខ** ជាតំបន់ស្ថិតនៅក្នុងភូមិសាស្ត្រលើខ្ពង់រាប និងជើងភ្នំដងរែក ដែលមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រតូចៗ ចំនួន ៨ ( ប្រាំបី ) គឺ ៖

តំបន់ ខ១ ៖ កន្លែងដុតខ្មោច សុន សេន ភូមិស្រះឈូក មានផ្ទៃក្រឡា០.០៦២ហិកតា ( សូន្យហិកតាសូន្យហុកសិបពីរ) ដែលមាននិយាមកា ៖ A (401217 ; 1581691) B (401197 ; 1581686) C (401207 ; 1581658) D (401229 ; 1581664) ។

តំបន់ ខ២ ៖ ទីតាំងផ្ទះសម្ងាត់ ប៉ុល ពត ខៀវ សំផន ជួន ជឿន ( ស្រែគំរូ) មានផ្ទៃក្រឡា៤.៤១២ហិកតា ( បួនហិកតាបួនរយដប់ពីរ) ដែលមាននិយាមកា ៖ A (397323 ; 1582693) B (397359 ; 1582892) C(397563 ; 1582892) D (397560 ; 1582691) ។

តំបន់ ខ៣ ៖ ទីតាំងការដ្ឋានដឹកជញ្ជូនរបស់តាម៉ុក មានផ្ទៃក្រឡា០.១២២ហិកតា ( សូន្យហិកតាមួយរយម្ភៃពីរ) ដែលមាននិយាមកា ៖ A (400994 ; 1577160) B (400999 ; 1577122) C(401030 ; 1577130) D (401024 ; 1577169) ។

តំបន់ ខ៤ ៖ បឹងអន្លង់វែង មានផ្ទៃក្រឡា ៤១៧ ហិកតា ( បួនរយដប់ប្រាំពីរ) ដែលមាននិយាមកា ៖ ភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

តំបន់ ខ៥ ៖ ផ្ទះតាម៉ុក សារមន្ទីរតាម៉ុក មានផ្ទៃក្រឡា១.៦១៤ហិកតា ( មួយហិកតាប្រាំមួយរយដប់បួន) ដែលមាននិយាមកា ៖ A (401247 ; 1574310) B (401344 ; 1574221) C (401307 ; 1574102) D (401213 ; 1574137) ។